**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្ដាល

លេខ :១២៣៨/សស.គក/១៥

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ, ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៥

# សេចក្ដីសម្រេច

## ស្ដីពី

## តួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់ គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍នៃគណៈចលនាមហាជន គណៈកម្មាធិការកណ្ដាល

**យោង**:-សេចក្ដីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាលលេខ ៣២៧/១៥ សស.គក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីតួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈចលនាមហាជន។

-ស្មារតីនៃអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល នាថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៥។

### <u>គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាលសម្រេច:</u>

**<u>ប្រការ១</u>**: គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ អក្សរកាត់ គ.ច.អ.ស មានតួនាទីធ្វើជាសេនាធិការជូនគណៈចលនាមហាជន ក្នុងការតម្រង់ទិស សម្របសម្រួល ជួយឧបត្ថម្ភ និងសហការជាមួយអង្គការ សមាគម ដៃគូអភិវឌ្ឍន៍ និងក្រុមការងារនានា ដែលបំពេញការងារក្នុងស្រទាប់មហាជន ក្រៅពីចលនាយុវជន ស្ត្រី កម្មករ និងនិយោជិត ដើម្បីបំផុសចលនាប្រជាជនការពារសមិទ្ធផលសង្គមជាតិ និងកសាងប្រទេសជាតិ ស្របតាមកម្មវិធីនយោបាយរបស់គណបក្ស។

**<u>ប្រការ២</u>**: គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ មានភារកិច្ចៈ

១-ស្រាវជ្រាវចងក្រងគោលការណ៍ គោលនយោបាយនៃការងារគណៈចលនាអង្គការសមាគម និងដៃគូអភិវឌ្ឍន៍ ដើម្បីដាក់ជូនគណៈចលនាមហាជននៃគណៈកម្មាធិការកណ្ដាល ពិនិត្យសម្រេច និងតម្រង់ទិសអនុវត្ត។

២-ពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពបណ្ដាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍។

៣-រៀបចំកសាង និងអនុវត្តផែនការសកម្មភាព គម្រោងកម្មវិធីនានាក្នុងគោលដៅសហការ សម្របសម្រួល ឬឆ្លើយតបជាមួយបណ្ដាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍។

៤-ពង្រឹងភាពជាដៃគូ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការល្អជាមួយបណ្តាអង្គការ សមាគម ដៃគូអភិវឌ្ឍន៍ជាតិ-អន្តរជាតិ និងភាគីពាក់ព័ន្ធនានា ដើម្បីកៀរគរធនធាន និងការគាំទ្រតាមមធ្យោបាយផ្សេងៗទៀត សម្រាប់បម្រើឲ្យការអនុវត្តផែនការនិងគោលនយោបាយរបស់គណបក្ស។

៥-ទាក់ទងសហការការងារល្អ ជាមួយគណបក្សគ្រប់ថ្នាក់ និងមុខសញ្ញានានា ដើម្បីបំពេញតួនាទី ភារកិច្ចឲ្យសម្រេចបានជោគជ័យ និងប្រសិទ្ធភាពខ្ពស់ជូនគណបក្ស។

៦-គ្រប់គ្រង ចាត់ចែង ថែរក្សាឯកសារលិខិតស្នាមរដ្ឋបាលរបស់គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ ឲ្យបានត្រឹមត្រូវ។

៧-ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនគណៈចលនាមហាជន។

៨-បំពេញភារកិច្ចផ្សេងទៀត ដែលគណៈចលនាមហាជនប្រគល់ជូន។

**ប្រការ៣**: រចនាសម្ព័ន្ធរបស់គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ មានលេខាធិការដ្ឋាន និងក្រុមទទួលការងារនៅតាមរាជធានី ខេត្ត។ លេខាធិការដ្ឋាន និងក្រុមនីមួយៗ មានប្រធាន ០១រូប អនុប្រធាន និងសមាជិកមួយចំនួន តាមការចាំបាច់ អាស្រ័យដោយគណៈចលនាមហាជន នៃគណៈកម្មាធិការកណ្តាល ពិនិត្យសម្រេច។

**ប្រការ៤**: របៀបរបបធ្វើការរបស់គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍៖

គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ ធ្វើការតាមរបបសមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវ ដោយត្រូវប្រជុំសាមញ្ញមួយខែម្តង និងអាចកោះប្រជុំជាវិសាមញ្ញបាន តាមការចាំបាច់។

-ប្រធាន ទទួលខុសត្រូវរួម លើរាល់ការងាររបស់គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍។ ពេលប្រធានអវត្តមាន ប្រធានត្រូវប្រគល់ភារកិច្ចជាលាយលក្ខណ៍អក្សរជូនអនុប្រធានណាម្នាក់ឲ្យទទួលខុសត្រូវជំនួស។

-អនុប្រធានទទួលបន្ទុកការងារមួយចំនួន តាមការប្រគល់ភារកិច្ចរបស់ប្រធានគណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍។

**ប្រការ៥**: ខុទ្ទកាល័យ គណៈចាត់តាំង គណៈចលនាមហាជន នៃគណៈកម្មាធិការកណ្តាល គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ និងស្ថាប័នគណបក្សដែលពាក់ព័ន្ធ ត្រូវប្រតិបត្តិតាមសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ. គណៈអចិន្ត្រៃយ៍

អនុប្រធាន

សាយ ឈុំ

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

លេខៈ ០៦៧៣ សស.គក
២៣៧

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វឌ្ឍនភាពសង្គម

ភ្នំពេញ,ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលខ្លឹមសារប្រការ៣ នៃសេចក្តីសម្រេច លេខ ១២៣៨/១៥ សស.គក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥

**យោង :** - សេចក្តីសម្រេចលេខ ១២៣៨/១៥ សស.គក ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០១៥ ស្តីពី តួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍នៃគណៈចលនាមហាជន គណៈកម្មាធិការកណ្តាល

- សំណើរបស់គណៈចាត់តាំងនៃគណៈកម្មាធិការកណ្តាល
- ស្មារតីអង្គប្រជុំគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៧

**គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល សម្រេច :**

**ប្រការ១ :** កែសម្រួលខ្លឹមសារប្រការ៣ នៃសេចក្តីសម្រេចលេខ ១២៣៨/១៥ សស.គក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពី តួនាទី ភារកិច្ច អង្គការចាត់តាំង និងរបៀបរបបធ្វើការរបស់គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍នៃគណៈចលនាមហាជន គណៈកម្មាធិការកណ្តាល ទៅជា :

" **ប្រការ៣ :** រចនាសម្ព័ន្ធរបស់គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ រួមមាន :

- **ថ្នាក់កណ្តាល** : ក្រុមទទួលការងារនៅតាមរាជធានី ខេត្ត និងលេខាធិការដ្ឋានមួយ ជាសេនាធិការ ។ ក្រុមទទួលការងារនៅតាមរាជធានី ខេត្ត និងលេខាធិការដ្ឋាន មានប្រធាន ១រូប អនុប្រធាន និងសមាជិកមួយចំនួនតាមការចាំបាច់ ។

- **ថ្នាក់រាជធានី ខេត្ត** : គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍នៃគណៈកម្មាធិការគណបក្សរាជធានី ខេត្ត មានប្រធាន ១រូប អនុប្រធាន និងសមាជិកមួយចំនួនតាមការចាំបាច់។"

**ប្រការ២ :** ខុទ្ទកាល័យ គណៈចាត់តាំង គណៈចលនាមហាជននៃគណៈកម្មាធិការកណ្តាល គណៈចលនាអង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ ត្រូវប្រតិបត្តិតាមសេចក្តីសម្រេចនេះ ។

កន្លែងទទួល
- ដូចប្រការ ២
- ឯកសារ

**ជ.គណៈអចិន្ត្រៃយ៍**
**អនុប្រធាន**

សាន.ន

**សាយ ឈុំ**